Tome II
Roeung Sdech Khmeng II
D. L. 12-11-5
B-8
D-80
N° 97
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL
ទ.ទ
164



ខទក្របសមុទ្រ ទី២

B-120-1466 ខ្ម

ឯយាយទៅជាស្រឡាំងកាំង ហើយតាំងស្ទូរទៀតតាំស្ទូតឲ្យរស់

យកពាក្យខាងណេះប្តូរខាងណោះ ស្វាឡើតេះតុះកេះក្របក

ក្សត្រីនឹកទៅពេញចិត្តដែរ ប៉ុន្តែការគេក្តី កុំឲ្យខក

ទើបតាំងក្តាប់ដៃខោកស្វាមក ថាហកឯងបេះបារ៉ែ... ៗ

ពានរខ្ញាបចិត្តលែងហ៊ានស្តី អង្គុយពាហីស្ងៀមច្រង់

ធិតាប្រាប់យាយតុំរង់នៅ ឲ្យស្តេចចូលទៅដល់បិតា ៗ

ប្រសិនស្រឡាញ់ខ្ញុំពេញចិត្ត សូមទ្រង់ករុណាមានមេត្តា

គួរកអ្នកផ្លូវចៅមហា កុំជឿតាមស្វាថាផ្តេះផ្តាស់ ៗ

ស្វាព្រលានមាត់ស្រែកក្រលួច ថាហ៊ឺងទ័ពស្លួចហើយអង្គម្ចាស់

ទោះស្តើសក្រិមយកចាញ់ឈ្នះ គេត្រូវការណាស់អ្នកស៊ើបជំ ៗ

ឯរឿងដណ្តឹងប្តីប្រពន្ធ ទោះមានទ្រព្យធន់យ៉ាងធំដុំ

គេតែងបែបបូរប្រមូលផ្តុំ ហេតុនេះម្ចាស់កុំថាខ្ញុំខូច ៗ

បើព្រមមិនព្រមដឹងជាមុន មានគុណគ្មានគុណរឿងនៅតូច

តិចលោកើតការថាស្វាខូច នោះដូចបាចដីខ្សាច់ជះខ្យល់ ៗ

ម្ចាស់អើយព្រះនាងទ្រង់ប្រណី ស្រុកសម័យប្តីទ្រង់កុំឆ្ងល់

ដឹងចិត្តគ្នាមុនសឹមចូលដល់ នឹងទើបចូលគាល់មិនព្រួយក្រោយ ៗ
ប្រសិនព្រះបីព្រមទៅរក នោះពេញរកស្នាម្ចាស់ខ្ញុំហើយ
បើទ្រង់មិនសព្វព្រះទ័យឡើយ ម្ចាស់សើយដឹងជាខ្នាស់យ៉ាងណា ៗ
របស់ក៏ខូចការក៏ខាន សំពៅសំប៉ាន់ហែរត្រៀបត្រា
ដើម្បីមកស្ដីតែវធិតា មុខជាឡេឡាកណ្ដាលផ្លូវ ៗ
បើរឿងនៅតូចការរកតិច យ៉ានមេ្ដចម្ចាស់ខ្ញុំក៏មិននៅ
ហេតុនេះសូមម្ចាស់អត់ទោសទៅ អាត្រាតយប់ព្រោះគ្មានគេដឹង ៗ
មួយទៀតបើលោស្ដីទៅហើយ បិតាព្រមឲ្យមិនមានខឹង
រកខុសព្រះទ័យស្រីខាន់ណាំង អំបិងតើម្ចាស់មានព្រួយទេ ៗ
រឿងនេះបើទូលព្រះបង្គំ ច្បាស់ព្រួយប៉ុនភ្នំព្រះសូមមេ៉
ដូច្នេះសូមម្ចាស់គួរលៃរេ តាមទ្រង់គិតគ្នេព្រះអង្គឯង ៗ
ធិតាស្ដាប់ស្វាបេះសាសង់ ពេញចិត្តណាស់ហោងគួរឲ្យស្ងែង
ទើបមានបន្ទូលមិនបង្អែង ច្នេះយាយតុបតែងពេលរាត្រី ៗ
សូមឲ្យស្ដេចយាងមកប្រាង្គប្រា ខ្ញុំនឹងសួរការសព្វសេចក្ដី
បើរឿងត្រូវគួរខ្ញុំប្រណី នោះមិនទាស់អ្វីទេយាយយើយ ៗ

ពាក្យចាស់ថាគូមិនដែលព្រាត់ ដើមឈើវារ៍ព័ទមិនលែងឡើយ
សំណាងកសាងត្រូវជួបហើយ ទោះបីប្រឆើយគង់មកដល់ ។
ជូនចាស់ព្កហើយទើបក្រោយណា នាងនាថថ្ងៃថ្វាអស់ពីផល
ប្រទានទ្រព្យផាកំណល់ វិលដល់ទីឋានមួយរំពេច ។
ស្តេចក្មេងឃើញហើយក៏សួរថា ម្តេចយាយយកផ្កាទៅថ្វាយស្តេច
រង្វាន់បានច្រើនឬបានតិច ធិតាថាម្តេចប្រាប់ខ្ញុំផង ។
យាយទូលថាម្ចាស់សូមសង្ឃឹម មិនគូគង់ទមមិងកន្ទង
បានសេនាម្ចាស់បេះសាសង ជួយផ្សុំគ្នាផងទើបបានព្រម ។
ធិតាផ្តាំថាដល់រាត្រី ពេលថ្ងៃសេនីយនៅប្រឈម
គិតការឲ្យស្រេចខ្លាចក្រែងទ្រម មើលពេលគួរល្មមសំយាងទៅ ។
ក្សុយត្រាព្កហើយត្រេកអរណាស់ យប់នេះអញច្បាស់ជួបឆោមឆ្ងៅ
នឹកថាបុត្រនាគសរប្កខ្មៅ ឆ្ងាញ់ប៉ុនណាទៅពុំដែលស្គាល់ ។
ទើបទ្រង់សើចលេងយាយមាលា លុះពេលនិទ្រារាត្រីដល់
តាក់តែងព្រះអង្គមិនសល់វល់ រំសាប់រំសល់ទ្រៀមចង់ទៅ ។
ថ្ងៃងពីក្សត្រីស្រីមានរាង ផ្តាំអស់កំលៀងដែលនិត្យនៅ

បើឃើញព្រះអង្គឲ្យបើកផ្លូវ  ខុសត្រូវស្រេចលើព្រះនាងទេ ។
ប្រាប់កូនពានរឲ្យចាំទ្វារ  ក្រែងព្រះរាជាប្រឡំគេ
ដ្បិតឃើញកីលៀងដេកទំនេ  នាំពីបាករមុនជាក្រោយ ។
ត្រាស់ក្បាងយាងចូលទីស័យណា  ខុរ៉ៃតែងគិតពុំមានស្បើយ
ពីតូចដល់ធំប៉ុណ្ណេះហើយ  គ្រានត្រើយមិនដែលជិតប្រុះសោះ ។
ភ័យអរៗ ញាក់ខ្ទរណ៍  ហាក់ដូចជាផ្គរខ្ចរឡើងស្មោះ
អារម្មណ៍នឹកខ្លាចព្រះទ្រង់យស  គឺមោះក្សត្រស្មារតីតិច ។
លុះយប់ជ្រួបយាមដែលសន្ធិយា  ក្សត្រាយាងដល់មួយរំពេច
ឃើញស្វាឈរយាមពុំមានគេច  ស្ទុះគេចបើកទ្វារជូនប្រញាប់ ។
ព្រះអង្គទតយល់ឃើញធិតា  ផ្ទុំកង្ក្រឡាបទុំស្រាប់
កេះស្វាថាបាចេញក្រៅឆាប់  ចាំស្តាប់ក្រែងមានការថ្លស់ធ្លោយ ។
ព្រះនាងយល់ភក្ត្រព្រះកុមារ  នឹកខ្មាសណាស់សាស្យៀមប្រដើយ
ស្តេចក្មេងទ្រង់ត្រាស់ថាប្អូនអើយ  ឃើញរៀមមកហើយធ្វើមិនស្បិត.
ចំពោះបានផ្តាំទៅដេប៉ា  ស៊ូខំយាត្រាតាំងយប់ស្ងាត់
មកដល់ប្រាង្គហើយគ្មានរំណិត  ប្អូនមួយតូចចិត្តពីរឿងអ្វី ។

នាងក៏ឈ្ងន់នេត្របៃមុខបំ ឃើញព្រះឧត្ដមគួរប៉ែតី
ប៉ុន្ដែការកេរ្ដិ៍ខ្លួនជាស្រី ទើបតាំងហាស្ដីសួរទៅថា ៗ
សូមទោសព្រះអគ្គយាងមកដល់ មន្ទីរមន្ទួលដែនសេមា
ពូជពង្សត្រកូលនាគឬយក្សា ឬក្សត្រប្រជាមន្ត្រីផង ៗ
ឬមួយស្ដេចស្ដែងគ្រងរដ្ឋា ដំបន់ថានណាប្រាប់នួនល្អង
មកនេះដំណើរការអ្វីហោង សូមសង់ដោយសួរតាមគួរសម ៗ
ស្ដេចបើកព្រះឧសព្រះឱង្ការ ប្រាប់កែវកន្និដ្ឋាគ្មានបារម្ភ
អូនអើយបងមកព្រោះមិត្រមុំ សូមសុំជាគូស៊្ប៊ីផ្ដូរសាប ៗ
ខ្លួនរៀមនាមឈ្មោះស្ដេចកុមារ ជាតិជាមនុស្សប្រសើរស្រេច
នគរស្ថាននាយគ្មានស្រីស្ដេច ទើបត្រាច់មកដល់ថាននាគ្គា ៗ
ម្យ៉ាងទៀតព្រះឈ្មោះពីរោះល្បី សាយសព្វផែនដីគ្រប់ទិសា
ថារូបប្អូនស្រីកបលក្ខណា បានចំប្រាថ្នាមកដល់អាយ ៗ
បើព្រមមិនព្រមកុំអន់អាក់ ដ្បិតតែរៀមក្ខុអកបម្លាយ
ខុសគ្គង់ម្ដេចម្ដាអាផ្សាស្រ័យ ចរណៃកុំតូចព្រះទ័យ្យា ៗ
ឆោមយង់នាងទ្រង់សុវណ្ណី តបព្រះបក្រីមិនរុញ្ញា

ចំណែកប៉ែកខ្លួនស្ងួនពុំឆ្ងា ពុំមែនខ្ញុំខ្លាឥតមេបារ ។
ពិតណាតែខ្លួនរូបខ្ញុំច្បាស់ ប៉ុន្តែមានម្ចាស់ថែរក្សា
បិតុខ្ញុំក៏ព្រមល្មមមេត្តា នៅព្រះបិតាមាតាទៀត ។
ហេតុនេះសូមទ្រង់ចូលតាមបង្គាប់ ឲ្យត្រូវសន្ទាប់កុំឲ្យឃ្លាត
ធ្វើតាមបុរាណសន្តានញាតិ ទើបពេញហៅជាតិត្រកូលក្សត្រ ។
ព្រះអង្គខិតចូលនាងខិតចេញ ដៃឃាត់មាត់ជេញមិនមានស្ងាត់
ស្តេចត្រាស់ថាទុជ្ជនប្រម៉ាត់ បើទោះជាសត្វគង់មេត្តា ។
យប់យន់ទៀតសោតជ្រៅណាស់ហើយ ដដៃគួរឡើយ ៗ ទៅដល់ម្ល៉ា
គួរណាស់ការណ៍ពិតដល់រៀមពី បំណាច់យាត្រាមកដល់អាយ ។
សព្វថ្ងៃអាឡៃតែថ្ងៃមួយ កើតទុក្ខសុខព្រួយព្រោះឆោមឆាយ
ជីវិតស្លាប់រស់មោះមិនស្ដាយ ស៊ូតែប្រកាយនឹងមាសមេ ។
នឹងថាឲ្យរំបេត្រឡប់ក្រោយ ប្អូននើយច្បាស់ជាមិនថយទេ
បេះដៃគោងជើងទាំកកេ ពាក្យនេះមិនទេពិតប្រាកដ ។
ធីតានឹកឡើងការណ៍តក្រៃ ក្សត្រីនៅស្ងៀមរោយសន្ទុត
ទ្រង់រួមរវើគ្មានជួរបត់ ជាគួរកុំសត់តាមហូរហៃ ។

ថ្ងៃពីស្ដេចនាគបមបក្ខព    លុះបាត់ធិតាយូរថ្ងៃខែ
ពុំឃើញឡើងគាល់មកជិតក្បែរ    ទ្រង់បែរសួរទៅពងបុត្រា ។
នៃបាសាគរបវរបូរ    ក្រមុំតើវាទៅឯណា
ពុំដែលឃើញមុខយូរមាសា    ឬវាមានការឈឺថ្កាត់អ្វី ។
ដូច្នេះបូរបាទៅឆាប់ៗ    ប្រញាប់សួរបងឲ្យដឹងក្ដី
រឿងហេតុម្ដេចម្ដាវិលវិញខ្ចី    កុំឲ្យព្រះបីព្រួយដោយសារ ។
សាគរបង្គំលាចុះផ្គង    សំដៅព្រះបងជាជេដ្ឋា
រីឯគីលៀងឃើញកុមារ    ស្ទុះស្ទាទៅទូលនាងក្សត្រី ។
បពិត្រម្ចាស់ប្អូនយាងមកហើយ    នាងនាថត្រានត្រើយទ្រង់កិតក័យ
រត់ចូលទៅលាក់ព្រះបក្រិ    ទឹងស្ងានោះនៃក្នុងសន្ធិយា ។
ទើបទ្រង់គង់ស្ងៀមទ្រៀមទិត្យនៅ    កុមារឡើងទៅដល់មាត់ទ្វារ
ឃើញបងថែបព្រួយហាក់រំភា    ហើយទ្រង់សួរថាម្ចាស់បងើយ ។
តើមានជម្ងឺរោគាអ្វី    ពុំស្រួលព្រះទ័យយ៉ាងណាឡើយ
ក្រៀមក្រំព្រះភក្ត្រហាក់មិនស្បើយ    បាត់មុខយូរហើយបិតាប្រើ ។
ឲ្យទូលបង្គំមកសួរបង    ប្រាយប្រាប់ប្អូនផងកុំសើរើ

នាងនាថក៏យកប់ព្រួយបន្ដី　ដំណើររៀមបងឈឺតែផ្ទៃ ៗ
បុកសៀតគ្មានស្រាក់ទេមាសស្នៃ　គំរប់បីខែនេះហើយនៃ
កុមាព្ទុះបោះអស់សង្ស័យ　រត់វៃទៅទូលដល់បិតា ៗ
ស្ដេចនាគជឿជាក់កូនឈឺពិត　មិនបានគិទិតរឿងយ៉ាងណា
គង់សៀមនៅទ្រៀមតាមធម្មា　ថ្ងៃងពីធីតានាងកែក្រោយ ៗ
ព្រួយណាស់ទើបទូលស្ដេចក្រុងថា　បពិតក៏ស្ដាម្ចាស់ប្អូនណើយ
យើងមុកទឹងមានទុក្ខដល់ហើយ　ព្រះសើយគោងគិតឲ្យប្រញាប់ ៗ
ប្រសិនព្រះបីប្រាប់កិច្ចការណ៍　ក្រោធឡើងកាលណាមុកជាស្លាប់
ព្រួសពីសខ្លាំងក្រៃខ្សែយ៉ាងធាប់　ទឹងវិនាសស្លាប់គ្មានសល់មួយ ៗ
ធ្វើម្ដេចពាក្យចាស់លោកថៃងបង　សប្បាយតែងសងបានក្ដីព្រួយ
ខ្ញុំប្អូនស៊ូតាមតែរៀមមួយ　សូមទេវតាជួយផ្សងតាមព្រេង ៗ
ស្ដេចមានបន្ទូលទឹងជាយោ　ថានៃសួនក្បួងមិនលេង
ប្រងប៉ិត្តឲ្យស្រួលកុំវង្វេង　បូរគេងឲ្យសុខចាំព្រឹកព្រាង ៗ
ប្អូនឡើងទៅគាល់ព្រះប៉ុក្ខា　ឲ្យក្ដារយ៉ាងម្ដេចត្រូវតែយាង
ត្រឡប់ប្រាប់រៀមកុំឲ្យឃ្លាង　ដូច្នេះព្រះនាងទើបសំគួរ ៗ

ខ្ញាល់ខ្លាំងសូមយើងតាំងរកផ្លូវ　ប្រុះមិនឲ្យនៅកើតម៉ង់មួរ
បើគេបរត់ភ្លាមហាក់ដូចផ្គរ　ទោះបើលោកសួរឆ្លើយសិនទៅ ។
លុះអារុនរះព្រះសុរិយា　នាងនាថយាត្រាមិនរង់នៅ
ឡើងគាល់មាតាដោះយោយៅ　ស្រីពៅពុំសូវតក់ស្លុតពេក ។
ដល់ហើយទុនកាយថ្វាយវន្ទា　ព្រះមេបែក្បាទ្រង់ត្រកៀក
ឃើញបុត្រមកដល់មានចិត្តត្រេក　ទើបស្រែកសួរកូនដោយរុះភាយ ។
កូនស្រីហេតុអ្វីបាត់មុខឃូ　ព្រះក៏គតបែបដូចពុំសប្បាយ
ឬមួយមានព្រួយអ៊ីកង្វល់កាយ　ប្ដូរចិតមកកាយជិតម្ដាយណ៎ា ។
លូកហ៍តឱបថើបបីត្រកង　ខ្ញិនហាក់សៅម៉ង់ខុះជម្ដា
យល់កន្ទព្រះទ័យមន្ទិលការ　ឱព៉ាញាប់ញ័រដោយគតិស្រី ។
ត្រាស់សួរថានែមាសម្ដាយអើយ　កូនមានថ្ងៃហើយរឿងហេតុអ្វី
សែបគុបនណាស្រស់ពីសី　គោងស្រីប្រាប់ម្ដាយឲ្យប្រញាប់ ។
វរត្ថនៅសៀមពុំថចា　ស្រក់ទឹកនេត្រាហើយទុនក្រាប
លើភ្លៅមាតាលែងសាស័ប　ដង្ហើមធំថប់ប្រសព្វគ្នា ។
សួរហើយសួរទៀតផ្ទៀតច្រើនដង　ទូនល្អងព្រួយខ្លាំងមិនពណ៌នា

ព្រះមេស្ដីដេថាពះវា  បើមិនស្ដីថាទៅវិញចុះ ៗ
ក្រមុំទូងើបឡើងពីភ្លៅម្ដាយ  កើតទុក្ខកងកាយដឹងខ្លួនខុះ
ព្រោះធ្វើបំពានលួចមានប្រុស  ក្រោកឡើងត្រេះត្រុះបង្គំលា ៗ
វិលដល់ប្រាសាទទូលស្វាមី  សេចក្ដីដែលយើងស្រឡាញ់គ្នា
ឥឡូវគោងគិតកុំវេរា  ដ្បិតព្រះមាតាដឹងការជាក់ ៗ
ស្ដេចក្មេងបន្ទូលផ្ទាស់ឆ្លើយថា  បើឈ្មោះយាត្រាទាំងពីរនាក់
នៅយូរកើតវេរមានគ្រោះថ្នាក់  បិតាដឹងជាក់ទឹងខ្សៃប្រាន ៗ
ដ្បិតបងមកនេះមានសំពៅ  យើងនាំគ្នាទៅឆាប់ទើបបាន
ត្រាស់ក្សាងឲ្យនាងតែងកល្យាន  ដឹកកូនហនុមានចាកចេញចរ ៗ
ណាមួយនាងព្រួយនឹកមាតា  ក្នុងទ្រូងខ្លោចផ្សាសែនភ័យអរ
ស្ដាយអស់ប្រាសាទកែវបវរ  មិនចង់ឃ្លាតចរចាកបុរី ៗ
ស្ដាយអស់ព្រៃព្រំពូកខ្នល់ខ្នើយ  ពិតាធ្លាប់កើយនៅថ្មី ។
ឥឡូវនឹងនៅឆ្ងាយព្រះបី  ឥឡូវនឹងស្ដីនាំយូការ ៗ
ម្ហូះហើយកាត់ចិត្តព្រាំទាំងទុក្ខ  ក្បែរត្រីយានមុខពីក្រោយស្វា
កណ្ដាលស្ដេចក្មេងចរយាត្រា  លុះត្រាតែដល់ទីសង្រែក ៗ

ហៀបនឹងឡើងជិះដោយប្រញាប់ ម្ហូសីទូលប្រាប់តាំងយំយែក

ថាឱព្រះបងកុំអាលដែក សូមជួយរំលែកកុំសង់កិន ៗ

ដ្បិតក្មួបសំពត់ពរក័ស្ដ្រា កញ្ជ្រូលមាសណាក្រហមឆ្អិន

សូមឲ្យម្ចាស់បងវិលវិញសិន ព្រោះប្អូននៅមិនទាន់ដាច់ចិត្ត ៗ

អញ្ជើញទៅយកកុំឲ្យយូ ប្អូនទុកកូនទូដែលស្អាងស្អិត

ស្ដួបក្មេងស្ត្រីហើយសែនអាណិត ហេតុដ្បិតតែស៊ូរគូស្នេហា ៗ

ទ្រង់ផ្ដាំថានែមាសបងអើយ នួននៅនេះហើយកុំខ្វេខ្វា

កុំពាល់សព្រឹកនេះឡើយណា ក្បែរការត់វិលត្រឡប់ក្រោយ ៗ

ទើបតែបានពាក់កណ្ដាលផ្លូវ ថ្ងៃនពីស្រីពៅពុំកន្ទើយ

ចាំយូរយុយដើងស្រស់ត្រានត្រើយ ក្មួបគិតហ៊ាតក៏យសព្រឹកហោង

រញ្ជួយញាប់ញ័រខ្សែប្រក៏ ដូចគេកន្ទាក់អ្នកយាមផង

នៅលើសំពៅស្រែកអឺងកង ម្ចាស់យកនួនល្អងបានមកហើយ,

ក៏នាំគ្នាស្រាវខ្សែឡើងឆាប់ ធិតាក៏ចាប់ជិះបណ្ដោយ

ពានរលោតតាមតោងពីក្រោយ លឿនលយឡើងលើដល់កេត្រា

ពល់ផងយល់ឃើញតែចរណៃ ក្បែរតែថ្ងៃពុំឃើញតាំងទូហា

ទើបទូលដន្ដឹងសួរទៅថា　　ម្ចាស់ប្រុះទៅណាពុំឃើញមក ៗ
ក្រមុទ្ធនាងភ័យញ័រឥតអាក់　　ប្រាប់ថារៀមរ៉ក់ស្ដេចវិលយក
កញ្ច្រាលមាសម៉ៃស្រីពន្លក　　ដឹងត្រឡប់មកហើយឬនៅ ៗ
ឲ្យខ្ញុំនឹងស្វាចាំកន្ទួង　　យានតែម្នាក់ឯងក្នុងទឹកជ្រៅ
ព្រោះការប្រញាប់មកឥឡូវ　　ផ្ដាំខ្ញុំកុំទៅពាល់ប្រាក់ ៗ
ប៉ុន្ដែខ្ញុំក្រូចរង្វើងកាន់　　ដោយគិតពុំទាន់ការជ្រាក់
ចាំយូរដៃគង់លើខ្សែទាក់　　ស្រាប់តែវាញាក់អ្នកទាញមក ៗ
ត្រាស់ភ្ញាងព្រះនាងស្រក់ទឹកភ្នែក　ទឹកថាឃ្លាតបែកព្រោះពន្លក
ព្រះអង្គទ្រង់ផ្ដាំឯងមិនយក　　ម្ទុះសំវិលមកខ្វល់យ៉ាងណា ៗ
នាងទួញរៀបរាប់មិនមានស្ងៀម　អាឡ័យព្រះរៀមជាកំស្ដ
ទើបអស់មន្ត្រីក្រាបទូលថា　　ម្ចាស់កុំសោកាព្រួយព្រះទ័យ ៗ
សូមឲ្យព្រះនាងយាងចូលក្នុង　　កន្ទួងបំរុងជូនម្ចាស់ថ្លៃ
ចំណែកម្ចាស់ប្រុះលោកមិនខ្វៃ　　ទ្រង់មានកែវផ្តែតាមទាន់ទេ ៗ
សូមគង់ឲ្យសុខទុក្ខឲ្យស្បើយ　　ស្ដេចយាងតាមក្រោយមិនបែរ
ឃើញខ្ញុំចាំយូរអស់ព្រះមេ　　ពល់វេជិតអត់អាហារហើយ ៗ

ហេតុនេះកុំតូចព្រះទ័យណា　ព្រោះវាចាំយូស៊ីគ្មានស្បៀយ
អាហារក៏អស់ណាម្ចាស់សើយ　ស្ដេចឡើយនឹងទៅដល់កាក　ៗ
ស្ដេចម្ដាសុំលែងទៅទៀត　ផ្លាស់ផ្ទៀតឲ្យតែរស់ជនមា
ក្សត្រីហួសស្ដីចូលនាវា　ផ្ទុំព្រួយទ័យព្យាសោកសៅម៉ង　ៗ
អស់ពួកសេនាមុខមន្ត្រី　ស្រាវយុតថ្កាខ្ទីឆាប់កន្ទង់
ហើយលើកក្ដោងបើកលឿនពេកហោង　កាត់ឆ្លងសមុទ្រទាំងយប់ថ្ងៃ
កាលនោះស្ដេចក្មេងវិលត្រឡប់　យកគ្រឿងបានគ្រប់ផ្លែកផលសែ
មកដល់ពុំឃើញស្រីថ្មើមថ្ងៃ　ព្រួយក្នុងព្រះទ័យសល់សែនធ្ងំ　ៗ
បាត់ទាំងសម្រែកបាត់ទាំងស្វា　ខំផ្អែកផលសាដោយវិទ្ធី
ក្អែកកៃដៃកាន់កែវពេជ្រម្នី　ដល់ទីសំពៅបាត់ទាំងអស់　ៗ
ក្រឡេកមើលទៅឃើញឆ្ងាយក្រៃ　ក្ដោងប៉ុនបាតដៃលឿនដូចហោះ
ស្ដេចទឹកគ្មានក្អកបន្តិចសោះ　កាន់កែវរត់ផ្លោះលើគគ្គ　ៗ
រត់តាមពុំទាន់ដោយឃ្លាតឆ្ងាយ　ព្រួយក្នុងអង្គកាយទឹកជាយា
ម្ទះសំបុនសួនទួនរហា　នៅក្នុងនាវាតែម្នាក់ឯង　ៗ

នឹងស្ទះទិទានពីមាតា　　　គួបចិត្តណាសាសែនចំបែង



ព្រោះតែកុត្រីខុសគេឯង　　　ប្រហ៊ឹមនាងតែងទួរសួរកូន ៗ
ដល់ហើយស្រែកហៅអស់បរិពា ពល់គ្នាទៅណាក៏បាត់សូន

ស្រីស្នំរត់ក្បែរហែកប់ផ្ទូង　　នាងស្ងួរថាកូនអញទៅណា ៗ
ទើបយានចូលផុតហួសមាត់ទ្វា　　ពុំឃើញស្ងួនក្សត្រធិតា
បើកអស់ទីទែនទាំងទ្វារ　　ទ្រង់សារស្ងួរអស់ក៏លៀងផង ៗ
អស់ស្រីទូលថាពុំបានដឹង　　ដំណឹងអំពីស្រស់ទងវង
ក្សត្រីស្រែកដេថាវៃនហង　　តិចត្រូវដំបងគ្មានប្រណី ៗ
អញឲ្យមេឯងថែកូនអញ　　បណ្ដោយស្រីឡាញ់លួចមានប្ដី
ម្សិលមិញអញឃើញមិនគាប់ប្បី　　ស្ងួរគ្មានដឹងអ្វីមេបុស្សា ៗ
រាងវៃបទ្រង់គកិសម្បុរអាប់　　អញស្ងួរមិនប្រាប់មិនបរា
ទីពឹងហងឯងគ្មានបានការ　　ឥឡូវណោះណានាំរត់បាត់ ៗ
នាងទូញនឹកដល់កូនសំឡាញ់　　គិតទៅគួរក្ដាញ់កង់ប្រម៉ាត់
មេះសំខ្នាស់ពស្ដួពន់ពេកក្ដាត់　　វាបាត់ថាឯងក្មើយ៉ាងខ្ទាំង ៗ
សង្ស័យមកលស់ហង់ហាក់ដូចទា　　រិតតែនាំគ្នាជួយបិតបាំង
នាងសោកស្ដើលអស់ទាំងផ្ទៃរាំង　　គាត់កាំងសារត្ទឹកស្រីពៅ ៗ
ក៏លៀងទូលថាឃើញតែក្មេង　　ស្ដេចមនុស្សមកលេងទីលំនៅ
ព្យុកមានតែវមុដទឹកជ្រៅ　　ប្រហែលយានទៅជាមួយដឹង ៗ

កាលមកឮថាព្រោះតែស្រី សង្រែករវៃចុះដល់ណាង
ទូលម្ចាស់កុំអាលទ្រង់ខ្វាល់ខឹង សូមគិតការនឹងទាន់ថ្មី ១ ៗ
មហេសីនាគស្ដាប់ដឹងជាក់ស្ដែង នាងទ្រង់កន្ត្រែងលែងចេញស្ដី
ថាឱពុទ្ធកមាសពិសី ម្ដេចរត់តាមប្ដីចោលសៃមា ៗ
ឃើញតែក្រឡាព្រះបន្ទំ យកប្ដីជាធំភ្លេចបីតា
ម្សិលមិញឪពុកមានឱង្កា ទៅត្រឹមមាតារអាវុធ ៗ
ម្ដាយសួរមិនធ្លាប់ក្រាបលើភ្លៅ ព្រោះពៅភ័យណាស់ខ្លាចម៉ែផ្ទួន
ប្រសិនព្រះមេដឹងប៉ុនផ្ទួន មិនឲ្យកូនស្ងួននាងព្រួយទេ ៗ
ជួយទូលព្រះបីទ្រអត់ទោស នៅតូចប្រឹនខុះល្ងង់ផងគេ
រៀបរាប់អាយនាយយុំលាយដេ ស្ទុះហោះរត់ចូលដល់ស្វាមី ៗ
ថាកូនមានប្រុសចោលសៃមា ប្ដីជាមនុស្សព្រៃគង់បូរី
ហេតុនេះសូមទ្រង់ជ្រាបសេចក្ដី គិតកែនសេនីយឫយ៉ាងណា ៗ
ឱ្យណ្ណាះស្ដេចនាគចមកំពូល ឮមហេសីទូលគប់ប្រការ
សន្ធប់រន្ធត់ត្រឡប់សា រឿងពីមេរ៉ៃថាឲ្យច្បាស់ ៗ
ស្ដាប់ជាក់ណោញាក់កេមចញ្ចើម ដង្ហើមខ្ពុលទឹកដល់អាកាស

ព្រះភ័គទំទែងឡើងផ្សែងផាស ដូចមាន់ក្រញាស់ញ័រកន្ទុយ ៗ
បង្រួមសរស្លាបមាត់ក្អិបក្អែត ព្រោះពិសអន្ទែតក្រញែងព្រុយ
ផ្អើលអស់ថ្គាមម្ហូរតែរពុយ ម្ហៃសីអង្គុយខ្ចាតចេញឆ្ងាយ ៗ
ត្រាស់ហៅសាគរពជបុត្រា អញប្រើបាសួរមេចន្ទ្រ
ហេតុម្ដេចទៅហើយហាក់ចូលដៃ មកគ្មានសង្ស័យថាពឈឺ ៗ
កុមារីគណាស់ញ័ររន្ធត់ ដង្គន់ក្រោបលុតកេសាព្រឹ
កូនទៅពៅថាមានជម្ងឺ បានព្រឹករត់ត្រឡប់វិញ ៗ
នៅក្នុងប្រាសាទគ្មានឃើញអ្វី ឃើញតែទាសីគាល់ពាស់ពេញ
ស្រពោនព្រះភ័គទុក្ខម្នោម្នេញ កូនក៏រត់ចេញផុតមន្ទិល ៗ
នាគស្រែកព្រះស្តេចមើលឥតបទ មេចូលប្រែកដក្រហឹមងិល
ព្រះនេត្រក្តៅផាសដូចកែវពិល ក្រឡាប់រអិលដូចស្មិលចូល ៗ
ថាមានមនុស្សព្រោបចិត្តធំ មកដល់បន្ទំនាំប្រមូល
ម្ទះសើយខ្ចបអស់វង្ស៍ត្រកូល ទើបងើបឡើងចូលហៅសេនា ៗ
ហើយ ៗ រៀបពល់យាន់ឆាប់ ៗ នឹងគាលទៅចាប់ចោរម្នុស្ស
ត្រាស់ប្រាប់សាគរកុមារ៉ . ចូរបាតែនពល់ប្រញាប់វៃ ៗ

គះគ្រឹកញាប់ញ័រខ្លួនផល្ងសា　　បែកក្បុះកក្សាមាខ្លាំងពេកក្រៃ
ល្អក់ទឹកផ្អូកផ្អើលអស់ហ្វូងត្រី　　ផ្អើលតាំងបក្សីពួកគ្រុឌា　　ៗ



នាគរាជស្រែកប្រាប់អស់ពួកពល ឃើញវាកុំអាលខាំទុំពោ

ចាំទុកឲ្យអញមើលមុខវា លុះដល់មាត់ទ្វារលើស្រមុច ៗ

ថ្ងៃនីពាហ្វូនគ្រុឌសត្វបក្សី បានឃើញចំណីដាក់ចំហុត

ហើរដេញកោន៍ស្វាបឆាបផុត ៗ នាគកែតក់ស្លុតរត់ត្រឡប់ ៗ

នឹងទល់រិទ្ធគ្រុឌាពុំបាន វិលវិនទីឋានសែនស្ងោស្ងប់

តាមកូនមិនទាន់ខឹងចំប្រប់ សញ្ជឹងសញ្ជប់ស្ងប់ស្ងៀមនៅ ៗ

និទានស្តេចគ្រុឌកាលរត់តាម ទឹកនេត្រហាមរក់ស្នាមពៅ

ប្រទះកោត្រាផ្សែងចតនៅ ពាក់កណ្ដាលផ្លូវជិតកោះមួយ ៗ

ស្តុកស្តិនពួកឈ្មួញអ្នកជួញព្រែ ស្តេចគ្រុឌរត់ក្បែរជួបគេស្ងួយ

ពានិចស្រែកសួរថាអើក្មួយ បានអ្វីដើពួយលើទឹកបាន ៗ

អ្នកមានរិទ្ធីមោះហិមា រត់លើគង្គាយ៉ាងចំណាន

ចូលជិតសូមសួរសោះរំខាន ចិត្តហ៊ានក្លាហានគ្មានខ្លាចទឹក ៗ

ក៏ត្រាព្រុះហើយឈប់ឆ្លើយថា ខ្ញុំមានកែវណាល្អពន្លិក

រត់លើដលសាលៀនសន្ទឹក ចេញដើររមានរកមានជោគជៃ ៗ

ពានិចបៅកែទឹកស្រឡាញ់ ថាពេលនេះអញគិតកែខៃ

សុំដូរឲ្យបនដំបងវៃ ទើបត្រាស់ថាហៃថ្លៃសូមចិត្ត ៗ
ខ្ញុំក៏មានទ្រព្យមួយពូកែ អ្នកដូរខ្ញុំដៃខ្សែប្រសិទ្ធ
ដំបងវាយឯងវៃលែងគិត បើប្រើឲ្យមិត ៗ ទាល់ស្លាប់ ៗ



ស្ដេចឈានជើងឡើងលើគ្រែ ចិត្តចង់ដឹងការស្បូវសាសប
ណាមួយមានកិបយ៉ាងប្រញាប់ ណាមួយគិតចាប់ឆក់ដំបង ។
ដើម្បីឲ្យបានរិទ្ធីច្រើន បូកកែវបានកើនគ្រាន់ស៊ីសង
ទ្រង់ស្ទួរពានិបថាមើលបង មានរិទ្ធចំណងសូមល្បងមើល ។
បើពេញចិត្តខ្ញុំ ៗ មិនថា ទើបនាយគេគ្រាប្រើតាមព្រិល
ដោចិត្តស្រែកបង្ឃួយរងើល តាមញាប់អង្រើលដូចបង់មែន ។
ស្ដេចឃើញធ្វើព្រមមិនតេងតាង កាន់ហុចម្នាក់ម្នាងមិនសល់សែន
រួបហើយទ្រង់លាចាកទីនេះ បទបែនបាត្តិបគេបសូមកាន់ ។
ដ្បិតតែស្រឡាញ់កែវខ្លាំងណាស់ ឥឡូវឃ្លាតប្រាស់គ្នាជាក់ស្រុន់
សូមថើបដោយបែកទ្រព្យកំណាន់ ពានិបក៏កាន់ហុចម្នីម្នា ។
ស្ដេចគ្រងចាប់បានកែវហើយណា ចុះពីគ្រែមិនរេព
ផ្ទុកផ្ទោះរំពេចលើគគ្រា អ្នកឈ្ងញទៅជាស្រឡាំងកាំង ។
បាត់មាត់បាត់កដូចគេបុក នៅពុំស្រណុកក្ដៅចិត្តខ្លាំង
ផុតស្ដីនិយាយបែបហងហង គ្មានអ្វីប្រណាំងទាន់កែវទេ ។
ស្ដេចខំរត់តាមសំពៅខ្លួន ទំពុំជួបជួនថ្ងៃជ្រៀងជ្រែ

ជិតដល់ចូលដែនទគរ ខ្វល់ណាស់ស្រែកដេពួកសេនីយ
ឡេងនឹកលល់គ្នាចាំលំនៅ ហ៊ាននាំស្រីទៅចូលបុរី
ចោលអញម្នាក់ឯងដូចកូនខ្វី ឯណាមន្ត្រីក្រមជំរួត ៗ
សែនទាក់យណាស់ស័កតិតូចធំ ក្រាបថ្វាយបង្គំមិនហ៊ានអួត
ដោយខ្លាចអំណាចគ្មានអំនួត ទើបនាំគ្នាព្រួតទូលសេចក្តី ៗ
ថាកាលដែលញោបខ្សែប្រាក់ គិតស្មានបមប័ក្ខជាបក្រី
អរណាស់ដោយចាំយូខែបិ ខ្វះប៊ីរត់ស្រាវខ្សែយុតថ្កា ៗ
ខ្វះទៀតចាំស្រាវឯងស្រែក ខ្វះហូទឹកភ្នែកអត់អាហារ
ម្ចាស់ហើយដល់ចាំយូមាសា តវណាគោក្តាក៏គ្មានសល់ ៗ
យុតថ្កាក៏ស្រាវសំពៅផាក់ ប្រាក់ក៏ឡើងឃើញនាងធ្លល់
នាវាសាត់ខ្វះក៏ណាល់ ទើបភ័យរបល់បាត់កន្ទែង ៗ
ណាមួយអង្ករក៏ជិតអស់ សល់ផៀតត្រីរស់ពីរបីស្នង
មន្ត្រីជំនុំគ្នាតប់តែង គេឯងស្រុះគ្នាវិលនគរ ៗ
គិតថាម្ចាស់គង់តាមទាន់ទេ រសៀលថ្ងៃជ្រែអស់រឹករវ
ដោយរឹទ្ធអំណាចកែវអំពរ មកទាន់ដេទរតាមព្រះទ័យ ៗ

ហេតុនេះសូមទ្រង់មេត្តាទោស　កិច្ចការត្រូវខុសសូមប្រណី
សូមយាងអញ្ជើញទតម្ចាស់ស្រី　ស្តេចក្មេងហួសស្តីមេត្រីស្នៀម ។
យាងចូលឃើញនាងក្របសមុទ្រ នាងអង្គុយលុតសំពះរៀម
យំសើមភ្នែកហើមដូចភ្នែកមៀម　ក្ស័ត្រារត់ក្រាមថ្នមមហេសី ។
ស្រណេះស្រណោចមិនបេះអស់　អាឡៃអាឡោះប្រពន្ធប្តី
បន្តិចលិចដល់ចូលបុរី　មនុស្សផងត្រាសស្រែកឈរត្រេបត្រា ។
អស់ពួកចាស់ក្មេងមិនខ្វល់ខ្វៅ ជីដូនតាចៅរត់ប៉ាស់តា
សុទ្ធតែបងប្អូនស្តេចកុមា៉　អរណាស់ដោយសារឃើញកូនមក ។
អស់ទាំងឪពុកអស់ទាំងម្តាយ　រត់មើលប្រញាយទាំងជ្រុលជ្រក
ចង់ឃើញក្រមុទ្ធឆោមពន្លក　មួយពួកកូនមកដល់ស្រុកហើយ ។
កញ្ច្រាលកញ្ច្រៀវដោយបានសុខ ជួបម្តាយឪពុកទុក្ខក៏ស្បើយ
ស្តេចក្មេងត្រាស់ថានែប្អូនណើយ ដល់ស្រុកបងហើយរៀបខ្លួនប្រាន
នាងនាដ្ឋតែងគ្រឿងរត្នបវរ　ល្អអើយពេញល្អយ៉ាងចំណាន
ស្តេចតែងសម្ភារម្ភុជស្បូវកាន　កលិយាននាងតែងខៀនបរបាច់ ។
ដៃកាន់កែវម្នីភ្លឺរចិត្តោង　ដំបងវែងគ្រប់ប្រដាប់

វ័ធភ័គផូផង់សមបំណាច់ ម្រាមដៃតាំងដប់សុទ្ធគ្រាប់ពេជៗ
ល្អល្អះដោយគ្រឿងលៀងអម្ចត់ ពុជញ្ញាក់មាត់ស្មើរលើវិ
សសើរស្នាថាមិនភ្លេច ភ្នែកមើលមិនព្រេចមិនបេះភ្អែតៗ
ក៏គ្រានាំនាងជាមហេសី សែនិយហៃហាមហូរតាមហេតុ
ចុះចាកសំពៅនាវាវែត ត្រដុំត្រដែតតតមានកែ ៗ
ស្ដេចនាំងយានដល់ផ្ទះអាត្មា ជួបជុំមាតានៅព្រះបី
ជីតាជីដូនបងប្អូនប្រុសស្រី សប្បាយឥតបីអ្វីប្រៀបបាន ៗ
ទើបនាំប្រពន្ធសំពះសួរ សេចក្ដីសំគួរក្នុងសន្ដាន



មានវៃចឹកសិមអីប៉ុន្មាន គូគឹមគ្រប់ប្រាណគ្មានទិសតាស ។
ដោយនាង ១ ធ្លាប់ជាតិជាស្តេច ពីបាកសំរេចហៅពាក្យពស្រ្ត
ខុះត្រូវតិចតួចតែពីសពាស ក្រាសធំនៃចាំថ្ងៃក្រោយ ។
ថ្ងៃពីកាលចុះផុតភេត្រា ពួកពលសេនាដែលស្តេចឲ្យ
ឃើញក្មេងនាំនាងទៅបណ្តោយ មិនត្រឡប់ក្រោយបូលរំដ្គៃដ ។
អាម៉ាត្យតាំងអស់ឡើងក្រាបទូល បមអ្កដកំពូលគ្រងបុរី
ជាដ្បិតស្តេចក្មេងដល់ហើយនៃ យកបានកែវស្រីក្រមុំទ្លា ។
រូបភងល្អល្អាស់ពេញត្រអាល បីដូចដែលកាលឃើញវិហ៊ារ
សំបុកសំទ្រង់វង់សោភា ទឹងរកពារនាប្រៀបពុំបាន ។
ឥឡូវនាំយកទៅផ្ទះហើយ ម្ចាស់សើយសូមដ្រាបតាមដើមដាន
ព្រហ្មទត្តទ្រង់ពុឈ្មោះយ៉ាវម៉ាន ហាក់អណ្តែតប្រាណបានស្ម៉ីគា ។
ទើបមានទុក្ករត្រាស់បង្គាប់ ឯងទៅឆាប់ ១ ហៅពួកវា
ឲ្យនាំក្យគ្រឹមកម្មា កុំឲ្យយូរយាត្រាឥឡូវ ។
សេនីយរត់ដល់ផ្ទះកុមា ស្រែកហៅទៅថាតាំងពីផ្លូវ
ស្តេចមានបន្ទូលឲ្យអ្នកទៅ កុងក្រានេះក្បូវកុំសៅម៉ង ។

ឆាប់ៗ ឲ្យទាន់ពេលវេលា នាំស្រស់តុំភាយកទៅផង

ថ្វាយដល់ចមប័ក្ខក្ស័ត្រច្បាស់ច្បង នេះម្ដងកុំសង៊ៃក្រែងយូរការ ។



ស្ដេចក្មេងឆ្លាស់ឆ្លើយទៅវិញថ្វាត់ អ្នកទូលមហាក្ស័ត្រកុំសាវ៉ា

ដោយបងល្បងចេះបំណោះប្រាណា ខុសត្រូវសន្តានសូមអត់ទោស ៗ

ចប់ប៉ុណ្ណោះ

អ្នកកែប្រែ ; " សាយ - ខេង - ហៅ-គឿង "

សៀវភៅនេះមានជាវជុំ និងលក់រាយ នៅផ្ទះបីត្រូបនឹង
លក់សៀវភៅលេខ ២២៩ ផ្លូវវើរដង់ ទល់មុខផ្សារស្តូន
ថ្មី ក្រុង ភ្នំពេញ

បើលោក-អ្នកត្រូវការប្រញាប់ ឲ្យទៅសួរយក
ពីផ្ទះ ហោង-ថៃ នៅផ្សារស៊ីញ៉ែកមាត់ទន្លេ ផ្ទះលេ
២១ ផ្លូវកេស៊ីស្វរិត្តិ ព្រោះមានផ្ញើទុកនៅកន្លែងនោះ

ថ្លៃ ៦៛០០

រោងពុម្ព ម៉ាន-ហ៊ើ ភ្នំពេញ
លេខ ៨៣ ផ្លូវហ្សស៊ីញី
Imp. Man-Huê P.-Penh